វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ១៨ ខែ មករា ២០១៨**

ចំណុចសំខាន់ៗអំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺៈ

- សមាគមអចលនវត្ថុរំពឹងទុកថានឹងមានការរីកចម្រើនបន្តទៀតនៅក្នុងប្រទេសកម្ពុជា
- សេដ្ឋកិច្ចវៀតណាមមានការរីកចម្រើននៅក្នុងឆ្នាំ២០១៨ អ្នកជំនាញរំពឹងថាកំណើននឹងឈានដល់កម្រិតលើសពីការរំពឹងទុកក្នុងឆ្នាំ២០១៩
- ភាពរឹងមាំរបស់អ្នកប្រើប្រាស់(Consumer resiliency) ជាគន្លឹះសម្រាប់បង្ហាញអំពីរូបភាពសេដ្ឋកិច្ចអាមេរិក ប៉ុន្តែមិនមានទិន្នន័យដោយសារតែការបិទទ្វាររបស់រដ្ឋាភិបាល

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### សមាគមអចលនវត្ថុរំពឹងទុកថានឹងមានការរីកចម្រើនបន្តទៀតនៅក្នុងប្រទេសកម្ពុជា

ប្រធានសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុ កម្ពុជា (CVEA) បានបង្ហាញពីទស្សនវិស័យដ៏វិជ្ជមានមួយចំពោះវិស័យអចលនវត្ថុនៅកម្ពុជា នៅក្នុងបទសម្ភាសន៍ជាមួយសារព័ត៌មានភ្នំពេញប៉ុស្តិ៍។

យោងតាម CVEA តម្លៃអចលនទ្រព្យបានកើនឡើងជាមធ្យម១៥% រៀងរាល់ឆ្នាំ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារភាពរឹងមាំនៃវិស័យធនាគារ ស្ថេរភាពនយោបាយ កំណើនសេដ្ឋកិច្ច និងការកើនឡើងនៃទុនវិនិយោគផ្ទាល់ពីបរទេស (FDI)។

នៅក្នុងឆ្នាំ២០១៨ តម្លៃដីបានកើនឡើង២០% ខណៈពេលដែលអគារលំនៅដ្ឋាន និងពាណិជ្ជកម្មបានកើនឡើងប្រហែល ១០%។ CVEA រំពឹងថាស្ថានភាពវិស័យអចលនវត្ថុនៅកម្ពុជានឹងនៅតែបន្តរឹងមាំក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។

### តារាងប្រចាំសប្តាហ៍ៈទុនវិនិយោគផ្ទាល់ពីបរទេសរបស់កម្ពុជា

តារាងសប្តាហ៍នេះ បង្ហាញពីលំហូរវិនិយោគផ្ទាល់ពីបរទេសរបស់ប្រទេសកម្ពុជាចាប់ពីខែមករាឆ្នាំ២០១៦ រហូតដល់ខែមិថុនាឆ្នាំ២០១៨ ។ ការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងត្រីមាសទី២ នៃឆ្នាំ២០១៨ មានចំនួន ៨៣១,៧ លានដុល្លារ

អាមេរិក ពោលគឺកើនឡើង១,៤% បើប្រៀបធៀបទៅនឹងត្រីមាសមុន។

ការវិនិយោគផ្ទាល់ពីបរទេសបានកើនឡើងជាបន្តបន្ទាប់នៅឆ្នាំ២០១៦ ប៉ុន្តែបានធ្លាក់ចុះនៅក្នុងត្រីមាសទីមួយ និងត្រីមាសទីបី នៃឆ្នាំ២០១៧។ បន្ទាប់ពីការធ្លាក់ចុះរយៈពេលខ្លី វិនិយោគផ្ទាល់ពីបរទេសបន្តកើនឡើងវិញ និងមានទំហំធំជាងមុននៅត្រីមាសទី១ នៃឆ្នាំ២០១៨ ។

**ការវិនិយោគផ្ទាល់ពីបរទេសរបស់កម្ពុជា(គិតជាលានដុល្លារអាមេរិក)**




ប្រភព៖ ធនាគារពិភពលោក

ឡើងក្នុងកម្រិតខ្ពស់បំផុតនៅក្នុងកំឡុងទសវត្សរ៍ចុងក្រោយនេះ គឺ ៧,១%។ កំណើននេះត្រូវបានគេរំពឹងថានឹងនៅតែរឹងមាំនៅកម្រិត ៦,៩% ក្នុងឆ្នាំ២០១៩ ដែលលើសពីកម្រិតដែលបានសន្មតនៅក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមឆ្នាំ ២០១៩ របស់វៀតណាមដែលមានត្រឹម ៦,៨% ។

នៅក្នុងសិក្ខាសាលាមួយនៅទីក្រុងហាណូយ កាលពីថ្ងៃទី ២០ ខែធ្នូ កន្លងទៅនេះ នាយកវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច និងគោលនយោបាយវៀតណាម លោក ង្វៀន ឌុកថាញ់ បានលើកឡើងថា៖ វៀតណាមអាចនឹងទទួលអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ក្នុងនោះរួមមាន កិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយនិងរីកចម្រើនសម្រាប់ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (CPTPP) និងការផ្លាស់ប្តូរផលិតកម្ម ដែលបណ្តាលមកពីសង្គ្រាមពាណិជ្ជកម្មរវាងអាមេរិក និងចិន។

ទោះជាយ៉ាងណា លោកបានព្រមានថា លក្ខខណ្ឌអំណោយផលរបស់អន្តរជាតិ អាចនឹងមានឥទ្ធិពលលុះណាតែមានកំណែទម្រង់ស្ថាប័ន ការបន្តធ្វើឲ្យប្រសើរឡើងនូវបរិយាកាសពាណិជ្ជកម្ម ការរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចដ៏ល្អ និងការផ្លាស់ប្តូរដោយយកចិត្តទុកដាក់ លើគំរូកំណើនសេដ្ឋកិច្ចរបស់វៀតណាម។

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### សេដ្ឋកិច្ចវៀតណាមមានការរីកចម្រើននៅក្នុងឆ្នាំ២០១៨ អ្នកជំនាញរំពឹងថា កំណើននឹងឈានដល់កម្រិតលើសពីការរំពឹងទុក ក្នុងឆ្នាំ២០១៩

តាមរយៈរបាយការណ៍មួយដែលចេញផ្សាយកាលពីថ្ងៃពុធ ដោយវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច និងគោលនយោបាយវៀតណាមនៃសាកលវិទ្យាល័យសេដ្ឋកិច្ច និងធុរកិច្ច បានបង្ហាញថា៖ កាលពីឆ្នាំមុន សេដ្ឋកិច្ច វៀតណាម បានកើន

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ភាពរឹងមាំរបស់អ្នកប្រើប្រាស់(Consumer resiliency) ជាគន្លឹះសម្រាប់បង្ហាញអំពីរូបភាពសេដ្ឋកិច្ចអាមេរិក ប៉ុន្តែមិនមានទិន្នន័យដោយសារតែការបិទទ្វាររបស់រដ្ឋាភិបាល

បន្ទាប់ពីទទួលរងនូវឥទ្ធិពលពីសង្គ្រាមពាណិជ្ជកម្ម និងការធ្លាក់ចុះនៃទីផ្សារភាគហ៊ុន សេដ្ឋកិច្ចអាមេរិកនឹងពឹងផ្អែកលើភាពរឹងមាំនៃការទិញទំនិញរបស់អ្នកប្រើប្រាស់ ខណៈកំពុងប្រឈមមុខទៅនឹងការធ្លាក់ចុះដែលអាចកើតមានឡើង។

ប៉ុន្តែ យើងមិនដឹងអំពីឥរិយាបថរបស់អ្នកប្រើប្រាស់ នៅក្នុងរដូវកាលទិញទំនិញ សម្រាប់ថ្ងៃបុណ្យណូអែលនោះទេ ដោយសារតែអង្គភាពពាណិជ្ជកម្ម ដែលជាអ្នកទទួលបន្ទុករៀបចំស្ថិតិសម្រាប់ការលក់រាយ នៅតែចិតក្នុងការសម្រាក នៅឡើយ ដោយសារតែការបិទទ្វាររបស់រដ្ឋាភិបាល។

ប្រសិនបើការបិទទ្វារនៅតែបន្ត ទិន្នន័យប្រាក់ចំណូលផ្ទាល់ខ្លួន និងទិន្នន័យនៃការចំណាយនៅចុងខែមករា ក៏ត្រូវពន្យារផងដែរ។

សេដ្ឋវិទូ និងវិនិយោគិនមួយចំនួនបានបង្ហាញការព្រួយបារម្ភថា បើគ្មានទិន្នន័យច្បាស់លាស់ស្តីពីបច្ចុប្បន្នភាពបរិយាកាសសេដ្ឋកិច្ចនោះទេ ធុរៈជននានានឹងមានភាពស្ទាក់ស្ទើរក្នុងការវិនិយោគដែលអាចជាសក្តានុពល ដែលរួមចំណែកក្នុងការបន្ថយភាពកើនឡើងរបស់សេដ្ឋកិច្ច។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះរួមមាន៖ ផ.ស.ស. របស់ប្រទេសចិន កូរ៉េខាងត្បូង ប្រ៊ុយណេ និងហ្វីលីពីន ក៏ដូចជា ការសម្រេចចិត្តនូវអត្រាការប្រាក់របស់ប្រទេសជប៉ុន សិង្ហបុរី និងម៉ាឡេស៊ី។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃច័ន្ទ ទី២១ ខែមករា</u>

- ផ.ស.ស. របស់ប្រទេសចិនក្នុងត្រីមាសទី៤ ឆ្នាំ ២០១៨
- ឧស្សាហកម្ម ផលិតកម្មរបស់ចិន សម្រាប់ខែធ្នូ
- ការលក់ទំនិញរាយរបស់ចិន សម្រាប់ខែធ្នូ
- តុល្យភាពពាណិជ្ជកម្ម របស់ថៃ សម្រាប់ខែធ្នូ

<u>ថ្ងៃអង្គារ ទី២២ ខែមករា</u>

- សន្ទស្សន៍តំលៃផលិតកររបស់កូរ៉េខាងត្បូង សម្រាប់ខែធ្នូ
- កំណើនផ.ស.ស. របស់កូរ៉េខាងត្បូងក្នុងត្រីមាសទី ៤ ឆ្នាំ ២០១៨
- ភាពគ្មានការងារធ្វើរបស់តៃវ៉ាន់ សម្រាប់ខែធ្នូ
- អតិផរណារបស់ហុងកុង សម្រាប់ខែធ្នូ
- ផ.ស.ស. របស់ប្រ៊ុយណេក្នុងត្រីមាសទី៣ ឆ្នាំ ២០១៨

<u>ថ្ងៃពុធ ទី២៣ ខែមករា</u>

- តុល្យភាពពាណិជ្ជកម្មរបស់ជប៉ុន សម្រាប់ខែធ្នូ
- ការសម្រេចចិត្តលើអត្រាការប្រាក់របស់ធនាគារជប៉ុន
- អតិផរណារបស់ម៉ាឡេស៊ី សម្រាប់ខែធ្នូ
- អតិផរណារបស់សិង្ហបុរី សម្រាប់ខែធ្នូ
- ការលក់រាយរបស់តៃវ៉ាន់ សម្រាប់ខែធ្នូ

<u>ថ្ងៃព្រហស្បត្តិ៍ ទី២៤ ខែមករា</u>

- ការសម្រេចចិត្តអត្រាការប្រាក់របស់កូរ៉េខាងត្បូង
- ផ.ស.ស. របស់ហ្វីលីពីន ក្នុងត្រីមាសទី៤ឆ្នាំ ២០១៨
- ការសម្រេចចិត្តអត្រាការប្រាក់របស់ម៉ាឡេស៊ី

<u>ថ្ងៃសុក្រ ទី២៥ ខែមករា</u>

- ទំនុកចិត្តអ្នកប្រើប្រាស់នៅកូរ៉េខាងត្បូងសម្រាប់ខែមករា
- ការលក់រថយន្តថ្មីរបស់ថៃ សម្រាប់ខែធ្នូ
- សន្ទស្សន៍ តម្លៃទំនិញអ្នកប្រើប្រាស់របស់ជប៉ុន សម្រាប់ខែមករា
- ផលិតកម្មក្នុងវិស័យឧស្សាហកម្ម របស់សិង្ហបុរី សម្រាប់ខែធ្នូ
- ការវិនិយោគផ្ទាល់ពីបរទេសរបស់ឥណ្ឌូនេស៊ី សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨